# ការសំភាសន៍របស់កែវ ហ៊ុន

កៈ អ្នកធ្វើការសំភាសន៍ឈ្មោះ ណៃ ហ៉ត ខៈ អ្នកដែលត្រូវគេសំភាសន៍ឈ្មោះ កែវ ហ៊ុន

កៈ ចាស! អ្នកមីងជាមុនដំបូង ខ្ញុំសូមធ្វើកិច្ចស្វាគមន៍អ្នកមីងផងដែរ ដែលបានធ្វើការសំភាសន៍ជាមួយខ្ញុំ។ ចឹងការសំភាសន៍មួយនេះ ធ្វើឡើងនៅថ្ងៃទី២៥ ខែ០៩ ឆ្នាំ២០១៦។ ចឹង តើអ្នកមីងមានអារម្មណ៍យ៉ាងម៉េចដែរ សំរាប់ការសំភាសន៍មួយនេះ?

ខៈ អត់មានអារម្មណ៍ម៉េចទេ គ្រាន់តែថាឆ្ងល់ចង់សួរយ៉ាងម៉េច អីម៉េចចឹងទៅណា។ បើសួរចំទំនងឆ្លើយ ក៏ឆ្លើយទៅ។

កៈ អត់អីទេ អ្នកមីងដោយសារសំនួរទាំងអស់នឹង អ្នកមីងឆ្លើយទៅអត់មានប៉ះពាល់អីទេ គឺវាល្អទាំងអស់។ ចឹងអ្នកមីង ខ្ញុំសុំស្គាល់ឈ្មោះរបស់អ្នកមីងផង តើអ្នកមីងមានឈ្មោះអ្វីដែរ?

ខៈ ឈ្មោះ កែវ ហ៊ុន។

កៈ តើឈ្មោះកែវ ហ៊ុននឹងជាឈ្មោះទាំងត្រកូល ឬគ្រាន់តែជាឈ្មោះពិតដែរ?

ខៈ ជាឈ្មោះពិត។

កៈ ជាឈ្មោះពិតរបស់អ្នកមីង ឈ្មោះពេញតែម្តងណោះអ្នកមីង?

ខៈ ឈ្មោះ កែវ ហ៊ុន។

កៈ ចាស! ចឹងឈ្មោះកែវ ហ៊ុនជាឈ្មោះពេញរបស់អ្នកមីងតែម្តងណោះ?

ខៈ នឹងហើយ។

កៈ ដូចជាឈ្មោះរបស់អ្នកមីង មានទៅដូចនឹងអត្តសញ្ញាណប័ណ្ណរបស់អ្នកមីងតែម្តង?

ខៈ នឹងហើយដូចគ្នាទាំងអស់។

កៈ ចឹងអ្នកមីងមានឈ្មោះហៅក្រៅទៀតទេ?

ខៈ អត់ទេមានឈ្មោះតែមួយនឹង។

ក៖ ហើយឈ្មោះនឹង ក៏ជាឈ្មោះមកពីកុមារភាពផងដែរ។

ខ៖ តាំងពីតូចរហូតដល់ចូលវ័យហាជាង។

ក៖ តើអ្នកណាជាអ្នដាក់ឈ្មោះឱ្យអ្នកមីងមួយនឹង?

ខ៖ ម្ដាយជាអ្នកដាក់ឱ្យ ម្ដាយឪពុក។

ក៖ តើអ្នកមីងនៅសិក្សា ឬក៏អ្នកមីងបញ្ឈប់ការសិក្សាហើយ?

ខ៖ ឈប់យូរហើយ តាំងពីអាយុដប់ឆ្នាំ។ រៀនបានប្រហែលជាខ្ទង់ប្រាំមួយឆ្នាំ
រៀនថ្នាក់កុមារឋាន ពីដើមគេហៅថ្នាក់កុមារឋាន។

ក៖ ថ្នាក់កុមារឋាននឹង ជាថ្នាក់ទីប៉ុន្មានដែរអ្នកមីង?

ខ៖ ថ្នាក់ទីពីរ ទីបីនឹង។ ឥលូវនិងថ្នាក់ទីពីរ ទីបី បើពីដើមគឺថ្នាក់ទីប្រាំ
តែបើថ្នាក់ទីប្រាំគេនឹងអន់ណាស់។ ពីដើមមិនមែនដូចឥលូវទេណា ថ្នាក់ធំមកដាក់ថ្នាក់តូច
ថ្នាក់តូចមកដាក់ថ្នាក់ធំទេ។

ក៖ ចឹងអ្នកមីងបានបញ្ឈប់ការសិក្សានៅអាយុដប់ឆ្នាំ។ តើនៅជំនាន់របស់អ្នកមីង
បានរៀនសិក្សាភាសាអ្វីខ្លះដែរនៅពេលនោះ?

ខ៖ អត់ រៀនតែខ្មែរ អត់បានរៀនអីទេ បានរៀនតែខ្មែរ។ មួយជំនាន់នោះរៀនតែខ្មែរ
មិនមានភាសាអង់គ្លេស ភាសាបារាំងអីទេ។ បើពីដើមថ្នាក់គេទីមួយ ទីពីរគឺថ្នាក់ធំណាស់
មិនដូចឥលូវនិងទេ។ ថ្នាក់កុមារឋាននិងគឺថ្នាក់ទីបួន ទីបី។

ក៖ និយាយជំនាន់នោះគេហៅថាថ្នាក់កុមារឋាន
ប៉ុន្តែសម័យយើងឥលូវគេហៅថាថ្នាក់បឋមសិក្សា វាខុសគ្នា។ អ្នកមីងដូចជាអាចចេះសរសេរ
និងអានអក្សរខ្មែរដែរទេ?

ខ៖ អានអត់ដាច់ទេ អានបានតែឈ្មោះខ្លួនឯង
ឈ្មោះម្ដាយនិងឈ្មោះរបស់ឪពុកតែប៉ុណ្ណឹងទេ។

ក៖ ចាស! ចឹងល្អមែនទែន។

ខ៖ ដល់ឈ្មោះរបស់គេផ្សេងទៀត អត់ចេះទេ។

ក៖ ដោយសារអ្នកមីង ចេះអានឈ្មោះ។

ខ៖ អានិងដោយសារយើង កាលណោះយើងវៃគ្នាបាញ់គ្នាជំនាន់នោះ។
រួចណាមួយយើងចេះតែរត់ទៅមើលក្នុយផង ក្នុយនៅឯភ្នំពេញកូនរបស់បង។
គាត់ឡើងយន្តហោះទៅ យើងជាអ្នកមើលទៅ ព្រោះអីបងថ្លៃធ្វើធំផ្កាយបួន។
ដល់ពេលឥលូវនៅតែកូនទេ ឪពុកម្ដាយរបស់ពួកវាគេសំលាប់ចោលអស់ហើយ។

ក៖ ចឹង តើអ្នកមីងកើតនៅទីណាដែរ?

ខ៖ កើតនៅនឹង។

ក៖ កើតនៅនិង នៅក្នុងប្រទេសកម្ពុជាមែន?

ខ៖ នឹងហើយ។

ក៖ អ្នកមីងអាចជួយរៀបរាប់ដល់ខ្ញុំបន្តិចបានទេ ដែលអ្នកមីងបានកើននៅភូមិ ឃុំ ស្រុក ខ័ណ្ឌ ខេត្តអីចឹងណា?

ខ៖ កើតនៅភូមិល្វា ឃុំល្វា ស្រុកព្រៃឈរ ខេត្តកំពង់ចាម។ កើតនៅនឹង
អត់មានកើតនៅកន្លែងណាផ្សេងទេ។

ក៖ ចាស! អ្នកមីង តើអ្នកមីងមានអាយុសព្វថ្ងៃប៉ុន្មានដែរ?

ខ៖ អាយុបើមិន៥៤ ក៏៥៥ដែល ដោយសារខ្ញុំអត់ចាំដែល។

ក៖ ចាស! ថា៥៥ចុះអ្នកមីង។ បើគិតតាមសុរិយាគតិ តើអ្នកមីងកើតនៅក្នុងឆ្នាំណាដែរ?
សុរិយាគតិនឹង ជាឆ្នាំសត្វទាំង១២។

ខ៖ ពស់ ឆ្នាំរោង។

ក៖ មានន័យថាអ្នកមីងកើតនៅក្នុងឆ្នាំរោង ពស់ឆ្នាំម្សាញ់តើ។

ខ៖ មិនមែនទេពស់ នាគរាជ។

ក៖ អូ! នាគរាជឆ្នាំរោង។ ខ្ញុំចង់សួរទាក់ទងនិងការរៀបអាពាហ៏ពិពាហ៏របស់អ្នកមីង
នៅថ្ងៃខែឆ្នាំណាដែរ?

ខ៖ យើងអត់បានរៀបការផង គ្រាន់តែយើងស្រលាញ់គ្នាតែម្តង។

ក៖ ចឹងជំនាន់ណោះ គេរៀបការដោយរបៀបយ៉ាងម៉េចដែរអ្នកមីង?

ខ៖ ជំនាន់នោះ យើងអត់មានរៀបអត់មានអីទេ។

ក៖ ចឹងការរៀបអាពាហ៍ពិពាហ៍របស់អ្នកមីង បានរៀបចំពីឪពុកម្តាយ
ឬក៏អ្នកមីងទាំងពីរស្រលាញ់គ្នា?

ខ៖ អត់ទេ ស្រលាញ់គ្នាតែម្តង ពីព្រោះអីឪពុកម្តាយស្លាប់អស់ហើយ។

ក៖ ចឹងនៅពេលអ្នកមីងស្រលាញ់គ្នា ឪពុកម្តាយស្លាប់ហើយ។

ខ៖ ចាស!

ក៖ តើអ្នកមីងបានជួបប្តីរបស់អ្នកមីងដោយរបៀបណាដែរ?

ខ៖ យើងជួបគ្នានៅពេលទៅធ្វើការសំណង់។

ក៖ នៅពេលអ្នកមីងទៅធ្វើការសំណង់ បានជួបគាត់ជាលើកដំបូង។ តើជំនាន់នោះ
គេឲ្យថ្លៃបណ្តាការយ៉ាងម៉េចដែរ?

ខ៖ ជំនាន់នោះយើងក្រ ទើបតែដាច់ប៉ុលពត។

ក៖ តើថ្លៃបណ្តាការគេឲ្យប៉ុន្មានដែរអ្នកមីង?

ខ៖ អត់មានឲ្យទេ យើងស្រលាញ់គ្នាដោយចិត្តនិងចិត្ត។

ក៖ ចឹង តើអ្នកមីងមានបងប្អូនប៉ុន្មាននាក់ដែរ?

ខ៖ បងប្អូននៅតែពីរនាក់។

ក៖ អូ! ពីរនាក់ ចឹងអ្នកមីងជាកូនទីប៉ុន្មានដែរ?

ខ៖ ជាកូនពៅ បងប្អូនប្រាំនាក់។

ក៖ អ្នកមីងអាចជួយរាប់ឈ្មោះរបស់បងប្អូនអ្នកមីងទាំងប្រាំ ឲ្យខ្ញុំបានទេ?

ខ៖ បងគេឈ្មោះណុំ ទីពីរឈ្មោះណាំ ទីបីឈ្មោះអែប ទីបួនឈ្មោះសារឿន
ទីប្រាំពៅគេឈ្មោះកែវ ហ៊ុន។

ក៖ ដូចជាអ្នកមីងបានចាំនៅឆ្នាំសត្វទាំង១២ របស់ពួកគាត់ទេ?

ខ៖ អត់ចាំ។

ក៖ អូ! អត់ទេចឹងអ្នកមីង។ តើពីមុនរហូតដល់ឥលូវ អ្នកមីងបានជួយធ្វើខ្លះសំរាប់បងប្អូន
ទៅវិញទៅមក?

ខ៖ ដូចជាមិនបានធ្វើអ្វីទេ គ្រាន់តែបានជួយថា បើបងប្អូនមានធ្វើបុណ្យទានអី
គ្រាន់តែទៅជួយជាកំលាំងចឹងណា រឿងលុយកាក់យើងគ្មានទេ។

ក៖ ចឹង តើអ្នកមីងអាចនៅចាំពី ពេលវេលាដែលឪពុកម្ដាយរបស់អ្នកមីងបានកើតទេ?

ខ៖ អត់ដែលស្គាល់ទេក្មួយអើយ មិនដឹងជាពួកគាត់កើតយ៉ាងម៉េចទេ។
បើកាលឪពុកស្លាប់យើងនៅតូច ឪពុកស្លាប់ប្រហែលជាខ្ញុំមានអាយុ៧ ៨ឆ្នាំ
មិនដល់ផងមើលទៅតែខ្ញុំថាប៉ុណ្ណឹងចុះ។

ក៖ ចឹងអ្នកមីងអត់ដែលលឺពីយាយតារបស់អ្នកមីង និយាយអំពីឪពុកម្ដាយ។

ខ៖ អត់ដែល យាយតាបើនិយាយខាងម្ដាយ ពួកគាត់ស្លាប់យូរណាស់ហើយ
យើងកើតមិនទាន់គាត់ទេ ខ្ញុំអត់ស្គាល់ឈ្មោះពួកគាត់ច្បាស់ទេ។

ក៖ បើគិតពីអាយុរបស់ពួកគាត់មកដល់ឥលូវ ប្រហែលជាប៉ុន្មានដែរអ្នកមីង?

ខ៖ បើគិតទៅឪពុកស្គាល់សម្ដេចតា។

ក៖ សម្ដេចតាចូលទិវង្គតនៅព្រះជន្មប៉ុន្មានដែរ?

ខ៖ សម្ដេចតា៩០ប៉ុន្មានទេ។

ក៖ ៩៤ឆ្នាំ។ សំរាប់ឆ្នាំទាំង១២របស់ឪពុកម្ដាយ ក៏អ្នកមីងអត់ចាំដែលណោះ?

ខ៖ អត់ចាំ ដូចចាំតែថាគាត់ស្គាល់សម្ដេចតា។

កៈ តើអ្នកមីងមានចាំពី ជីវប្រវត្តិរបស់ជីដូនជីតារបស់អ្នកមីងទេ? តើពួកគាត់បានកើតនៅទៅកន្លែងណា ពេលណាដែរ?

ខៈ អត់ចាំទេ តែបើពុកចាំថាគាត់ក់តនៅឃុំល្វា ភូមិល្វា។

កៈ គាត់កើតនៅឃុំល្វា ភូមិល្វា ស្រុកព្រៃឈរ ខេត្តកំពង់ចាម។

ខៈ ស្រុកព្រៃឈរ ខេត្តកំពង់ចាម។ បើខាងម្តាយគាត់នៅខាងផ្តៅជុំ។

កៈ ភូមិ?

ខៈ អត់ដឹង ដឹងតែផ្តៅជុំចឹងម៉ង។

កៈ ចាស! អត់អីទេអ្នកមីង។

ខៈ ប្រហែលជាភូមិផ្តៅជុំ ឃុំអីចឹងម៉ង។

កៈ តើអ្នកមីងមានបានដឹង អំពីទីកន្លែងកំនើតរបស់ឪពុកអ្នកមីងទេ? ដូចជាគាត់កើតនៅភូមិណា ឃុំណា ខេត្តណាដែរ?

ខៈ គាត់កើតនៅឃុំល្វា ស្រុកព្រៃឈរ ខេត្តកំពង់ចាម។

កៈ ចាស! រួចចុះម្តាយ គាត់កើតនៅភូមិឃុំណាដែរ?

ខៈ ម្តាយគាត់កើតនៅផ្តៅជុំនឹង។

កៈ អ្នកមីងអាចជួយប្រាប់ពីភូមិឃុំបានអត់?

ខៈ អត់ចាំផង ស្គាល់តែភូមិផ្តៅជុំ ចំណែកឃុំវិញមិនដឹងជាឃុំអ្វី។ អត់ស្គាល់ទេ ពីព្រោះអីកាលណោះយើងនៅតូចៗដែល។

កៈ ចឹងអ្នកមីងមានចាំនៅទីកន្លែងកំនើតរបស់ជីដូនជីតារបស់អ្នកមីង ដូចជាភូមិឃុំស្រុកអីចឹង?

ខៈ អត់។

កៈ តើអ្នកមីងបានរស់នៅក្នុងប្រទេសកម្ពុជា បានប៉ុន្មានឆ្នាំដែរ?

ខៈ គាត់រស់នៅនិងប្រហែលបានអាយុ៦០ឆ្នាំដែល ពីមុនគាត់ខូច៦០ជាងអីនឹងមើលទៅ។

កៈ ដូចជាពួកគាត់ពីមុន មានធ្លាប់បានទៅរស់នៅក្រៅប្រទេសអ្វីដែរទេ?

ខៈ អត់មាន កើតរស់នៅតែក្នុងប្រទេសខ្មែរនឹង គាត់មិនដែលទៅណាទេ។

កៈ ធ្លាប់ផ្លាស់ប្តូរទីកន្លែងទេណោះ?

ខៈ គាត់នៅតែភូមិឃុំល្វានឹង។

កៈ អ្នកមីង ខ្ញុំចង់សួរទាក់ទងនិងពេលវេលាដ៏លំបាក នៅក្នុងជិវិតរបស់អ្នកមីង?
តើអ្នកមីងបានឆ្លងកាត់វា ដោយរបៀបណាខ្លះ?

ខៈ ពិបាកនឹងវាហួសពីពិបាកទៅទៀត មីងនិងរែកដីផងអីផង។
រកអង្ករចិញ្ចឹមក្មួយមិនចង់រស់ផង ចិញ្ចឹមក្មួយបីនាក់តែស្លាប់មួយ នៅសល់ពីរ។
បើនិយាយពីនោះវេទនាហួសពីវេទនាទៀត គ្មានបងគ្មានប្អូនឯណាជួយ
បងប្អូនស្លាប់ទៅនៅបងមួយ ប៉ុន្តែមិនដឹងជាគាត់នៅឯណាទេ។

កៈ ឥលូវអ្នកមីងឆ្លងកាត់មកដល់ឥលូវរាងធូរស្រាល់។

ខៈ រាងធូរបានតិចហើយក្មួយ ប៉ុន្តែទំរាំតែគ្រាន់បើ វេទនាសឹងតែពាក់កណ្តាលជិវិត។
ដើរឌុបដើរលក់ ខាត់ណាលក់ឃើញសព្វឃើញគ្រប់ ចិញ្ចឹមក្មួយដល់ស្លាប់មួយគឺក្មួយធំ។

កៈ ចឹងអ្នកមីងអត់មានកូនទេ?

ខៈ មានកូនមួយ ជាកូនប្រុសនឹងមានប្រពន្ធបានចៅមួយ វាមានកូនតែមួយទេ។

កៈ គាត់ឈប់រៀនហើយ?

ខៈ ឈប់ហើយ រៀនបានត្រឹមថ្នាក់ទីប្រាំពីរក៏ឈប់។

កៈ អូ! ប្រពន្ធគាត់មិញនឹងណោះ?

ខៈ នឹងហើយ។

កៈ ខ្ញុំចង់ដឹង ដូចជាអ្វីដែលអ្នកមីងចង់ចាំជាងគេនៅក្នុងជិវិតរបស់អ្នកមីង?
អ្នកមីងអាចជួយប្រាប់ខ្ញុំបានទេ តើជិវិតលំបាកដែលអ្នកមីងចង់ចាំជាងគេ
ពីមុនមកតាំងពីវ័យក្មេងរហូតដល់ឥលូវ?

ខ៖ ពិបាកនឹងហួសពីពិបាក ដោយសារយើងជាខ្លួនស្រីទៅរែកដី ជីកស្រះហើយយកអង្ករមកចិញ្ចឹមក្មួយ។ ទំរាំតែបានកូននាងអើយ អត់បានពីរថ្ងៃ បីថ្ងៃ ជីវិតរបស់មីងនេះនរណាក៏អាណិតដែល។ យើងរស់ស៊ីតាមកំលាំងញើសឈាម យកមកចិញ្ចឹមក្មួយ ក្មួយនៅតូចៗម្ដាយឪពុកពួកវាគេយកទៅសំលាប់ចោល។ នេះវេទនាក្នុងមួយឆាកជិវិតនេះ ដល់អាយុ៥០ជាងបានមានរាងងើបតិចៗ បានត្រឹមអាយុ៥៤បានងើបតិចៗ។ វេទនារកអ្វីប្រៀបផ្ទឹមគ្មានទេរឿងមីងណោះ។

ក៖ ចាស! អ្នកមីង ប៉ុន្តែឥលូវអ្នកមីងបានឆ្លងផុតនៅទុក្ខលំបាកទាំងនោះហើយ។

ខ៖ គ្រាន់តែថា បានហូបអីវាមិនគ្រប់ទេ នូវតែខ្វះចឹងលក់ដីតិចៗ មីងរើពីនេះទៅនោះ ពីនោះមកនេះ។ និយាយទៅមីងលក់ដីអស់ បី បួនកន្លែងហើយ រើចុះឡើងតែមិនទៅឆ្ងាយ។ គ្រាន់តែថាលក់ទៅ យើងបានកំរៃសល់តិចតួចនិង វាគ្រាន់តែបានសងគេទៅ គ្រាន់បានទិញរបស់ហូបចឹងទៅ។

ក៖ ដល់អ្នកមីងបានជួបនិងប្រវត្តិជួរចត់ចឹង តើបើអ្នកមីងបានរៀបអាពាហ៍ពិពាហ៍ ហើយមានកូន? តើកាលអ្នកមីងនៅក្មេងសង្ឃឹមថានិងធ្វើអ្វី នៅពេលធំឡើង?

ខ៖ កូនគាត់ដ៏មិនដឹងជាសង្ឃឹមធ្វើអ្វីដែល បើគាត់រៀនបានតិចធ្វើអីចេញ។ បើសង្ឃឹមថាបានធ្វើអី លុះត្រាតែកូនយើងនឹងរៀនបានច្រើន បើកូននឹងគ្នារៀនបានតិចដែលមិនដឹងជាធ្វើអីបាន មានតែធ្វើជាអ្នកបំរើគេ។

ក៖ កាលជំនាន់អ្នកមីងទៅរៀន តើអ្នកមីងបានលុយទៅសាលាប៉ុន្មានដែរនៅក្នុងថ្ងៃ?

ខ៖ តាមម្ដាយឲ្យតិចៗដែល ពីព្រោះអត់ពីឪពុកទៅមិនដែលងាយស្រួលទេ ក្មួយអើយ។ ពួកគាត់ចិញ្ចឹមកូនដល់ទៅប្រាំនាក់ ដល់ពេលអត់ពីឪពុកទៅ។ គាត់ស្លាប់តាំងពីឆ្នាំ៧០គត់ម៉េច យន្ដហោះបាញ់ត្រូវគាត់ក៏ស្លាប់ទៅ តាំងពីឆ្នាំ៧០គត់។ រួចជំនាន់នោះ មីងនៅតូចៗអាយុប្រហែល បើមិនប្រាំមួយឆ្នាំ ក៏ប្រាំឆ្នាំដែលមិនដល់ប្រាំពីរ ប្រាំបីទេជំនាន់នោះ។

ក៖ តើជំនាន់នោះ អ្នកមីងរៀននៅសាលាមួយណាដែរ?

ខ៖ សាលាល្វានឹង សាលារៀនដែលមានសព្វថ្ងៃនឹង។

ក៖ សាលាល្វាណោះអ្នកមីង។ កាលជំនាន់មុន គេដាក់ឈ្មោះសាលានឹងឈ្មោះអ្វីដែរអ្នកមីង?

ខ៖ មិនដឹងជាសាលាអីទេនាងអើយ ភ្លេចបាត់ហើយ។ រៀនបានយូរដែលហើយ ហើយឥលូវមីងអាយុ៥០ជាងដែលហើយ។ មិនដឹងសាលានិងឈ្មោះអីទេ បើភ្លេចអស់ទៅហើយ។

ក៖ និយាយទៅអ្នកមីងមានធ្លាប់បានធ្វើការងារផ្សេងទៀតទេ នៅក្នុងជិវិតក្រៅពីការងាររែកដីលក់បន្លែអីនឹង?

ខ៖ ផុតពីនឹងទៅ មានតែទៅធ្វើចំការទៅទន្លេ ទៅកាត់ស្មៅវែសណ្តែងវែរអីនិង ដើរកាប់ដើមសណ្តែងបាយ សណ្តែងសៀង។ មីងមិនដែលបានទំនេរដូចគេ ចេះតែរកទៅ ទៅទន្លេ ទៅចំការផង ដល់ខែកាត់ស្លឹកថ្នាំក៏ទៅកាត់ទៅ ទៅកាត់ទៅរើសទៅ។

ក៖ អ្នកមីងពិតជាកំសត់ណាស់នៅជំនាន់នោះ។

ខ៖ មីងមិនដែលបានទំនេរទេ បើមិនទៅបានអីចិញ្ចឹមក្មួយ ក្មួយទុកចោលនៅផ្ទះពីរនាក់បងប្អូន។

ក៖ ផ្ទះរបស់អ្នកមីង បានសាងសង់ដោយខ្លួនឯង ឬក៏អ្នកមីងជួលគេមកធ្វើ?

ខ៖ ផ្ទះនឹងធ្វើដោយខ្លួនឯង។

ក៖ អត់មានជួលជាង ជួលអីទេអ្នកមីងណោះ?

ខ៖ ជួលខ្លះដែល មិនមែនថាថាធ្វើពីរបីនាក់ឪពុកកូននោះធ្វើបានទេ។

ក៖ នរណាគេដែលបានបង្រៀនឲ្យពួកគាត់ចេះធ្វើផ្ទះ ឬក៏ចេះធ្វើដោយខ្លួនឯង?

ខ៖ អត់ដឹងទេក្មួយ ប្រហែលជារៀនចេះពីគេមកហើយ។ ដែលធ្វើដូចថា គេហៅទៅធ្វើផ្ទះថ្មទៅ ក៏ចេះតែរៀនមកពីព្រោះមួយឆាកជិវិតរបស់ប្តីប្រពន្ធខ្ញុំវេទនាមួយចប់។

ក៖ អ្នកមីងក្រៅពីលក់ដូរ តើអ្នកមីងមានជំនាញអ្វីផ្សេងទៀតទេ? ដូចជាជំនាញខាងធ្វើម្ហូប ឬជំនាញខាងត្បាញ ឬក៏ធ្វើអីផ្សេង?

ខ៖ អត់កើតទេក្មួយអើយ! មិនដែលសោះ។ បើយើងអត់ស្ទូវ មិនមែនអត់ស្ទូវទេគឺយើងអត់ចេះអក្សរតែម្តង ដល់ចឹងគេរកអ្នកធ្វើការ គេរកតែអ្នកដែលចេះអក្សរ។ បើយើងជាអ្នកដែលអត់ចេះអក្សរ ទៅធ្វើអីកើត ធ្វើវាមិនកើតទេ។

យើងមានតែប្រើកំលាំងខ្លួនយើង ទៅធ្វើជាអ្នកបំរើរបស់គេទៅ។ បេះសណ្តែងទៅ ជំរះស្មៅទៅ វែសណ្តែង រើស្លឹកថ្នាំទៅ។

ក៖ ដើម្បីកូនណោះ?

ខ៖ មិនមែនដើម្បីកូនទេ គឺដើម្បីក្ងួយ។

ក៖ អូ៎ កាលណោះអ្នកមីងចិញ្ចឹមក្មួយ?

ខ៖ ចិញ្ចឹមក្មួយ។

ក៖ ប៉ុន្មាននាក់ដែរ អ្នកមីង?

ខ៖ បីនាក់តែងាប់មួយ។

ក៖ ហើយចុះបងប្អូនរបស់អ្នកមីង ពួកគាត់អត់មានបានមកជួយនៅក្នុងកិច្ចការ?

ខ៖ ជួយយ៉ាងម៉េច បើពួកគេងាប់អស់ហើយ។

ក៖ អ្នកមីង អាចនៅចាំពីថ្ងៃខែពួកគាត់ស្លាប់ទេ?

ខ៖ ចាំអត់បានទេក្មួយអើយ បើកាលណោះជំនាន់ប៉ុលពត។

ក៖ ឈ្មោះដែលអ្នកមីងបានរៀបរាប់ពីខាងលើ នឹងមែនអ្នកមីង?

ខ៖ នឹងហើយ បងថ្លៃមួយ បងថ្លៃនិងគាត់ផ្កាយបូន។ ដែលមីងណាតែងរៀនៗ រត់ទៅមើលកូនឲ្យគាត់ ឡើងយន្តហោះនិងណា។ ប៉ុន្តែគេសំលាប់គាត់ចោលហើយ គេអារករគាត់និងផៀនត្នោត។

ក៖ ចឹបានជាគេសំលាប់គាត់ចឹងអ្នកមីង?

ខ៖ កាលណោះជំនាន់ប៉ុលពត យើងធ្វើធំគេមិនសំលាប់យើងចោល។ យើងធ្វើដល់ផ្កាយបូនហើយ មិនមែនឋានៈតូចឯណា។ ពួកទាហាន កាលជំនាន់ពីបួន ប្រាំខែមុនគេប្រកាសរកតើ គ្រាន់ថាវាអត់ចាំ គេប្រកាសរកអន្តរជាតិអាមេរិចកាំង។ គេប្រកាសរកកូនទាហានផ្កាយបូន ផ្កាយបីនិងណា គេជួយឲ្យតែយើងចាំ គ្រាន់តែថាមិនដឹងរកនរណាឲ្យជួយ បើយើងអត់ដឹង។

កៈ ចឹង តើអ្នកមីងអាចមានរឿងអ្វី ចង់ប្រាប់បន្ថែមទាក់ទងនិងជីវប្រវត្តិរបស់អ្នកមីង?

ខៈ ដូចជាអត់មានរឿងអីទៀតទេ គ្រាន់តែថាវាកំសត់និងវេទនា។

កៈ ចាស! ចឹងបើសិនជាអ្នកមីងអត់មានរឿងអ្វី និយាយដើម្បីបន្សល់ទុកនៅក្នុងរីខូដនិងទេ។ ចឹងសូមចប់នៅសេចក្ដីថ្លែងការណ៍ និងការសំភាសន៍របស់អ្នកមីង។

ខៈ និងហើយសុខសប្បាយ។

កៈ ហើយខ្ញុំសូមអរគុណ អ្នកមីងផងដែល
ដែលបានអង្គុយសំភាសន៍និងរៀបរាប់អំពីជីវប្រវត្តិរបស់អ្នកមីង
ឲ្យខ្ញុំបានស្ដាប់និងបានលឺពីភាពកំសត់របស់អ្នកមីងផងដែរ។
ហើយការសំភាសន៍និងអាចចេញជាឌីស ប្រហែលជាបី
បួនខែខ្ញុំនិងយកឲ្យអ្នកមីងទុកស្ដាប់ខ្លួនឯង។ ឌីសនិងគឺសំរាប់ស្ដាប់
នៅក្នុងក្រុមគ្រួសាររបស់អ្នកមីង និងសំរាប់កូនក្មួយរបស់អ្នកមីងចឹងណា។

ខៈ ក្មួយវាដឹងហួសពីដឹងទៅហើយ ពីព្រោះមីងនិយាយប្រាប់ពួកវាណោះ។
ពេលដែលមីងពិបាកចិត្តចឹង គឺមីងនិយាយប្រាប់ពួកវាហើយ។

កៈ អ្នកមីងចឹងខ្ញុំអាចសុំថតរូប របស់អ្នកមីងមួយសន្លឹក ពីរសន្លឹកបានទេ?

ខៈ ថតចុះ តែកុំឲ្យយកទៅដាក់បក្ខណាបក្ខណី។

កៈ អ្នកមីងចង់និយាយថា កន្លែងរបស់ខ្ញុំមិនមែនជាកន្លែងនយោបាយទេ
ហើយខ្ញុំធ្វើអ្វីទាំងអស់និងក៏អត់បានលុយដែល។

ខៈ ថតទៅ ខ្ញុំអត់ចិត្តអាក្រក់ទេ។

កៈ ខ្ញុំសូមបង្ហោះរូបរបស់អ្នកមីងបានអត់?

ខៈ បង្ហោះចុះ អត់មានហាមឃាត់អីទេ។

កៈ ចាសៈ អ្នកមីង ចឹងសូមអរគុណានូវពាក្យពេចន៍ទាំងឡាយដែលបានរៀបរាប់
ប្រាប់មកដល់ខ្ញុំតាំងពីដើមរហូតដល់ចប់ផងដែរ៕